# កិច្ចដោតជម ឬរៀបគ្រូនៅភូមិសំបួរ

បើពោលអំពីលាងអារក្ស ឬបញ្ចូលមេមុត មនុស្សភាគច្រើនតែងតែឮជាប់មករហូតហើយ ឥតដាច់ឡើយ។ កិច្ចលាងអារក្ស គេធ្វើឡើងដើម្បីដឹងគុណដល់អារក្សដែលបានជួយព្យាបាលជំងឺ ជង្កាត់ផ្សេងៗរបស់កូនចៅឱ្យជាសះស្បើយ ដ្បិតអារក្សគឺជាខ្មោចឬអមនុស្សដែលគេកាន់តាមខ្សែ ក្នុងគ្រួសារ ជួនកាលក៏ខ្សែខាងម្ដាយ ជួនកាលក៏ខ្សែខាងឪពុក។ ជាទូទៅ អ្នកភូមិសំបួរតែងតែ ប្រារព្ធពិធីលាងអារក្សជារៀងរាល់ឆ្នាំ ហើយគ្រួសារនីមួយៗតែងតែមកធ្វើរួមគ្នានៅថ្ងៃណាមួយ ក្នុងភូមិ ដោយគេធ្វើតែពេលយប់ប៉ុណ្ណោះ។ ពិធីលាងអារក្ស ត្រូវមានសំណែនឬគ្រឿងរណ្ដាប់ ច្រើនយ៉ាង និងត្រូវមានភ្លេងលេងកំដរពេងទៀតផង ដែលតម្រូវឱ្យមានការចំណាយច្រើនក្នុងការ ធ្វើកិច្ចនេះ។ ហេតុដូច្នេះហើយ អ្នកភូមិសំបួរដែលមានកាន់ខ្សែអារក្ស តែមានសេដ្ឋកិច្ចគ្រួសារមិន ធូរធារ បានប្រារព្ធពិធីមួយទៀតជំនួសវិញដែលគេហៅឈ្មោះថា "កិច្ចដោតជម" ឬ "កិច្ចរៀបគ្រូ"។ តើកិច្ចដោតជម ឬរៀបគ្រូមានលំដាប់លំដោយ និងអត្ថន័យបែបណាខ្លះ?

ជម គឺជារណ្ដាប់មួយប្រភេទដែលមានចំនួន៤ ធ្វើចេញពីដើមចេកដែលគេអង្កាន់ខ្លីៗ (រូបលេខ១) ខ្លះជាកំណាត់ដុំឈើក៏មានដែរ (រូបលេខ២) ព្រមទាំងមានប្រើប្រាស់ម្ជូចំនួន ៤សន្ទឹក ដែលគេមូលដោតនិងកំណាត់ចេកឬឈើនោះតែម្ដង។ រីឯពាក្យថា "រៀបគ្រូ" គឺសំដៅលើការរៀប គ្រឿងរណ្ដាប់ទាំងអម្បាមាណដែលគេសាងថ្មីខ្លះ និងបន្ថែមរបស់របរដែលមានស្រាប់ខ្លះ ដើម្បី រៀបថ្វាយដល់គ្រូ។ ហេតុនេះហើយ ទើបមានអ្នកខ្លះហៅថា ដោតជម និងខ្លះទៀតហៅថា រៀបគ្រូ ព្រោះថាន័យនៃឈ្មោះទាំង២គឺបំពេញន័យឱ្យគ្នាទៅវិញទៅមកដូច្នោះដែរ។ កិច្ចដោតជម ឬរៀប គ្រូ បើប្រៀបធៀបជាមួយនឹងកិច្ចលាងអារក្សយើងឃើញថា មានលក្ខណៈខុសគ្នាស្ទើរទាំងស្រុង មិនថាគ្រឿងរណ្ដាប់ និងកិច្ចពិធី។

កិច្ចដោតជម ឬរៀបគ្រូ គេមិនសូវជាលំបាកដូចកិច្ចលាងអារក្សឡើយ ព្រោះកិច្ចនេះ ចំណាយពេលត្រឹមតែមួយព្រឹក គ្មានភ្លេង មិនត្រូវការពេង មិនត្រូវការសែនព្រេន ផ្ទុយពីលាង អារក្សដែលត្រូវចំណាយពេលស្ទើរមួយយប់ពេញ ត្រូវការភ្លេងលេងកំដរ ត្រូវការពេង និងសែន ព្រេនវែងឆ្ងាយ។ ក្នុងលំដាប់លំដោយនៃកិច្ចដោតជម ជាដំបូងគេត្រូវរៀបចំគ្រឿងរណ្ដាប់ផ្សេងៗ រួមមាន ស្លាធម៌ធំមួយ ស្លាធម៌តូចចំនួន៤ និងជមក៏ត្រូវមាន៤ដូចគ្នាដែរ។ គ្រូខ្លះត្រូវការពៃ គ្រូខ្លះ ទៀតមិនត្រូវការទេពៃទេ (រូបលេខ៣)។ បន្ទាប់មកទៀត គឺជាការបញ្ជាន់រូបពីម្ចាស់នៃកិច្ចផ្ទាល់

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

ដែលការបញ្ជាន់រូបនៅពេលនេះគេមិនត្រូវការក្មេងលេងកំដរនោះឡើយ។ ក្រោយពីអារក្សបានចូលខ្លួនរូបស្នងមក សិស្សគុនដែលមកចូលរួមពិធីនេះ នាំគ្នារៀបរាប់អំពីទុក្ខលំបាកផ្សេងៗដែលសិស្សគុនកំពុងតែប្រឈម និងប្រាប់ពីបញ្ហាដែលសិស្សគុនមិនបានធ្វើកិច្ចលាងអារក្សថ្វាយដល់គ្រូថែមទៀតផង។ បន្ទាប់មកទៀត សិស្សគុនចាប់ផ្ដើមរៀបរាប់អំពីជំងឺដង្កាត់ដែលខ្លួនមាន និងពឹងពាក់ដល់គ្រូជួយមើលជំងឺរបស់ខ្លួនឱ្យជាសះស្បើយ (រូបលេខ៤-៦)។ ជាទូទៅ អ្នកស្នងរូបគ្រូអារក្សដែលមករៀបចំពិធីដោតជមឬរៀបគ្រូនៅភូមិសំបូរច្រើនតែជាមនុស្សស្រី។ ចំណែក ឯគ្រូវិញអាចជាមនុស្សប្រុសក៏មាន មនុស្សស្រីក៏មាន ដោយយើងអាចសម្គាល់បានអំពីគ្រូអារក្សថាជាប្រុសឬស្រីតាមរយៈសំឡេងនៃការនិយាយរបស់រូបស្នងជាមួយសិស្សគុន។

ជារួមមក កិច្ចដោតជមឬរៀបគ្រូមិនមែនជាកិច្ចពិធីដែលទើបតែកើតមានឡើងនោះទេ ដ្បិតប្រពៃណីនេះយើងមិនដឹងថាមានតាំងពីណាមក ហើយបានបន្តពីមួយជំនាន់ទៅមួយជំនាន់ឥតឈប់ឈរមករហូតហើយ។ កិច្ចដោតជមឬរៀបគ្រូ និងកិច្ចលាងអារក្ស មានលំដោយលំដោយនៃការរៀបចំខុសគ្នាក៏ដោយ តែអត្ថន័យគឺមានលក្ខណៈតែមួយដដែល គឺជាតបស្នងសងគុណដល់អារក្សដែលបានជួយថែរក្សាការពារនិងមើលថែសិស្សគុនទាំងឡាយ។ យើងអាចកត់សម្គាល់បានថា "លាងអារក្ស" សំដៅដល់ការធ្វើឱ្យអារក្សស្អាត ឱ្យអស់មន្ទិល រីឯដោតជមឬរៀបគ្រូ សំដៅដល់ការរៀបគ្រឿងរណ្ដាប់ដល់គ្រូអារក្ស។ សព្វថ្ងៃ បើទោះបីជាកិច្ចដោតជមមានលក្ខណៈងាយស្រួលជាង និងចំណាយថវិកាតិចជាងយ៉ាងណាក៏ដោយ ក៏អ្នកភូមិសំបូរតែងយល់ថា ពួកគាត់ចង់ប្រារព្ធពិធីលាងអារក្សច្រើនជាង ព្រោះលាងអារក្សបង្ហាញអំពីភាពអធិកអធម និងបង្ហាញអំពីវិសាលភាពធំធេងរបស់គ្រូអារក្សច្រើនជាងកិច្ចដោតជម៕

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ១៖ ជម



រូបលេខ២៖ ជម



រូបលេខ៣៖ ពៃសាលា



រូបលេខ៤៖ ការបញ្ចាន់រូប



រូបលេខ៥៖ រូបស្នង់ស្តោះផ្លុំដល់សិស្សគុន



រូបលេខ៦៖ រូបស្នង់ស្តោះផ្លុំដល់សិស្សគុន

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង